

# ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដង ចំពោះអំពើដដែល

## និយមន័យ

ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល ការពារបុគ្គលពីការកាត់ទោសពីរដងចំពោះអំពើដដែល។



ការហាមឃាត់នេះរួមបញ្ចូលនូវគោលការណ៍មិនចោទប្រកាន់ត្រួតគ្នា បកស្រាយសំដៅ "មិនចោទប្រកាន់ពីរដងចំពោះអំពើដដែល" និងធានាបុគ្គលណាមួយនូវសិទ្ធិរួចផុតពីការជំនុំជម្រះ ឬការដាក់ទណ្ឌកម្មចំពោះបទល្មើស ដែលពួកគេត្រូវបានកាត់ទោស ឬរួចផុតពីទោសចូលជាស្ថាពររួចហើយ តាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនៃប្រទេសនីមួយៗ។

គោលការណ៍នៃការមិនចោទប្រកាន់ត្រួតគ្នាពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងនឹងទ្រឹស្តីអាជ្ញាអស់ជំនុំដែលបកស្រាយថាបាន "វិនិច្ឆ័យរួចហើយ" និងមានន័យថា ការវិនិច្ឆ័យជាស្ថាពរដោយតុលាការ ឬស្ថាប័នមានសមត្ថកិច្ច ដាច់ស្រេចហើយ។ នីតិវិធីថ្មីជាប់ពាក់ព័ន្ធនឹងគោលបំណងដូចគ្នា មូលដ្ឋានច្បាប់ដូចគ្នា និងភាគីដូចគ្នាមិនអាចដំណើរការបានឡើយ។ ដូច្នេះ ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលនេះ អនុវត្តនៅត្រឹមពេលដែលមានសេចក្តីសម្រេចចូលជាស្ថាពរហើយ ឬម្យ៉ាងទៀតនៅពេលដែលបណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់អស់ផ្លូវតវ៉ា។



## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ




ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលត្រូវបានការពារក្រោមមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ" ។

### ច្បាប់ជាតិ



មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល "ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។" ហើយមាត្រា២៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានបញ្ចូលការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល។

# សារសំខាន់



ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល ផ្តល់ឱ្យមានការការពារតាមផ្លូវតុលាការដល់បុគ្គលដែលរងការរំលោភបំពានពីរដ្ឋ។ ការហាមឃាត់នេះការពារគោលការណ៍អាជ្ញាអស់ជំនុំ ដែលគោលការណ៍នេះផ្តល់នូវភាពជាចុងក្រោយ និងសុចរិតភាពចំពោះដំណើរការនីតិវិធីព្រហ្មទណ្ឌ ដូច្នេះហើយការពារបុគ្គលពីការគំរាមកំហែងជាបន្តបន្ទាប់នៃការធ្វើទុក្ខបុកម្នេញ និងការយាយីតាមរយៈការស៊ើបអង្កេត និងការកាត់ទោសម្តងហើយម្តងទៀតពីស្ថាប័នតុលាការចំពោះអំពើដ៏ដែល។



ការហាមឃាត់នេះការពារគោលការណ៍នៃភាពច្បាស់លាស់នៃច្បាប់ដែលពង្រឹងនូវប្រព័ន្ធយុត្តិធម៌។ ការហាមឃាត់នេះក៏ចៀសវាងការខ្វះខ្នាយធនធានច្បាប់សំខាន់ ដោយរារាំងនីតិវិធីជាច្រើនដោយតុលាការដដែល ឬផ្សេងទៀតចំពោះបទល្មើសព្រហ្មទណ្ឌដដែល។



ដូចនេះ ការហាមឃាត់នេះជាគោលការណ៍ ដែលសំខាន់ចំពោះការគ្រប់គ្រងយុត្តិធម៌ដ៏សមស្រប និងចៀសវាងការខុសឆ្គោយក្នុងការជម្រះក្តីដោយភាន់ច្រឡំនៃតុលាការ។

# ដែនកំណត់

សម្រាប់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលត្រួតពិនិត្យលើការអនុវត្តនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលមិនបាន៖



ហាមឃាត់ការកាត់ទោសឡើងវិញលើជនដែលត្រូវបានកាត់ទោសហើយ ក្នុងការអនុប្បវាទចំពោះអ្នកដែលស្នើសុំការកាត់ទោសឡើងវិញ។



ហាមឃាត់ការកាត់ទោសបុគ្គលឡើងវិញ បន្ទាប់ពីសាលាជម្រះក្តីជាន់ខ្ពស់បដិសេធការកាត់ទោសចោល។



ហាមឃាត់ការចាប់ផ្តើមការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌឡើងវិញ ប្រសិនបើត្រូវបានកែតម្រូវដោយ "កាលៈទេសៈពិសេស" ដូចជាការរកឃើញភស្តុតាងថ្មី។



ធានាថា បុគ្គលនឹងមិនត្រូវបានជំនុំជម្រះពីបទល្មើសព្រហ្មទណ្ឌដែលគោរពតាមយុត្តាធិការជាតិនៃរដ្ឋពីរ ឬច្រើនជាងនេះ។ ប៉ុន្តែ រដ្ឋត្រូវបានជំរុញក្នុងការបង្ការការជំនុំជម្រះឡើងវិញសម្រាប់អំពើដដែលតាមរយៈកតិកាសញ្ញាអន្តរជាតិ។



ការពារពីវិធានការវិន័យដទៃទៀតដែលមិនសមាមាត្រនឹងទណ្ឌកម្មព្រហ្មទណ្ឌសម្រាប់បទល្មើសដដែល។ ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលអនុវត្តទៅលើបទល្មើសព្រហ្មទណ្ឌតែមួយគត់ មានន័យថាការហាមឃាត់នេះមិនអនុវត្តចំពោះនីតិវិធីរដ្ឋបាល ឬរដ្ឋប្បវេណីឡើយ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden Sverige

People Change the World
Diakonia

cc BY NC SA